# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**

លេខៈ ៦០៤៥ សជណ-អក.ធប

# សេចក្ដីជូនដំណឹង

## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក **ចំនួន ៣៩ រូប** ដើម្បីចូលបម្រើការងារនៅ អង្គភាពបណ្ដាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

**១- បុគ្គលិកថែទាំជួសជុលត្រង់ស្វូម៉ាទ័រនិងប្រព័ន្ធបញ្ជា, បុគ្គលិកថែទាំជួសជុលឧបករណ៍ភ្ជាប់-ផ្ដាច់និងប្រព័ន្ធបញ្ជា, បុគ្គលិកថែទាំជួសជុលប្រព័ន្ធអគ្គិភ័យនិងប្រព័ន្ធបញ្ជាMV-LV, បុគ្គលិករោងជាងមេកានិកក្នុងអនុស្ថានីយ, បុគ្គលិកបច្ចេកទេសគម្រោងខ្សែបញ្ជូន, បុគ្គលិកបច្ចេកទេសគម្រោងអនុស្ថានីយ និង បុគ្គលិកទិន្នន័យបច្ចេកទេសសម្ភារ** ចំនួន ១៣ រូប

- បុគ្គលិកប្រចាំការអនុស្ថានីយរាម ចំនួន ០៥ រូប
- បុគ្គលិកប្រចាំការអនុស្ថានីយស្ទឹងហាវ ចំនួន ០២ រូប
- បុគ្គលិកប្រចាំការអនុស្ថានីយព្រះវិហារទី១ ចំនួន ០១ រូប
- បុគ្គលិកប្រចាំការអនុស្ថានីយកំពង់សីលា ចំនួន ០១ រូប
- បុគ្គលិកប្រចាំការអនុស្ថានីយរតនមណ្ឌល(ខេត្តបាត់ដំបង) ចំនួន ០១ រូប
- បុគ្គលិកប្រចាំការអនុស្ថានីយស្ទឹងត្រែង ចំនួន ០១ រូប

សរុបចំនួន ២៤ រូប

+បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន

**២- បុគ្គលិកថែទាំនិងជួសជុលខ្សែបញ្ជូន២៣០KV** ចំនួន ១២ រូប

+បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន
+បេក្ខជនត្រូវមានសុខភាពល្អ និងកាយសម្បទាមាំមួន អាចឡើងបង្គោលតង់ស្យុងខ្ពស់បាន

**៣-បុគ្គលិកត្រួតពិនិត្យបរិក្ខារអគ្គិសនី** ចំនួន ០១ រូប :

+បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សា វិស្វករអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Program AutoCAD
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន

៤- បុគ្គលិកវាយតម្លៃបរិក្ខារអគ្គិសនីផ្នែកខាងក្រៅ ចំនួន ០១ រូប និងបុគ្គលិកបូកសរុបការងារអនុស្ថានីយ ចំនួន ០១ រូប សរុបចំនួន ០២ រូប :

+បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្ដល់អាទិភាព ។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។**

*- **បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។**

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ ចន្ទ ០៤ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩

ជ. **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**កែវ_គន្ធា**

**<u>បញ្ជាក់</u>**
- សេចក្ដីជូនដំណឹងនេះ ធ្វើកាផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។